បណ្ណាល័យ ហ៊ុន សែន
ឆ្នាំ ២០០៣
895-9323
00010298
បណ្ណាល័យ ហ៊ុន សែន HUN SEN LIBRARY R.U.P.P. សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
បណ្ណាល័យ LIBRARY BUDDHIST INSTITUTE
២៣៩៣

# គុលឈិន

ប្រលោមលោកក្នុងប្រវត្តិសាស្ត្រ

ដោយ

លោកឧកញ៉ាវិបុលរាជសេនា

នូ កន



ចាត់ចែងបោះពុម្ពផ្សាយដោយ

សុន្ទ-ប៉ុលិន

បោះពុម្ព លើកទីពីរ រក្សាសិទ្ធិគ្រប់យ៉ាង

ព.ស. ២៥០៨ គ.ស. ១៩៦៤

ស្នាដៃលោក នូ កន (១៨៧៤-១៩៥០)

សៀវភៅបោះពុម្ពផ្សាយរួចហើយ ទាវឯក-សមុទ្រ តេជោ-សាមកុក-ពិម្ពានិពាន្ធ-មហាវេស័តាបស-បកិណ្ណក-កថា គោរព៧ប្រការ-ឥណាវ-គុណឈិន ។ ( រឿងគុណឈិន និងរឿងឥណាវ មានតែអក្សរសាស្ត្រលួចបោះផ្សាយម្តងរួចហើយ ។ រឿងឥណាវត្រូវគេកែឈ្មោះអ្នកនិពន្ធដាក់ជាសមាណរី ហើយទីដ៏ត្រូវប៉ិកែជាសម្រាយចំណែករឿងគុណឈិន ត្រូវគេបំបាត់ដាក់ឈ្មោះអ្នកនិពន្ធសូខ្យស៊ុង ) ·

រឿងដែលមិនទាន់បោះពុម្ព—រឿងគុណឈិនជាកំណាព្យ ( សូមបញ្ជាក់ថារឿងគុណឈិន អ្នកនិពន្ធបានសរសេរជាសម្រាយមុន ជាកំណាព្យក្រោយ ) — រឿងល្អដាននកក៏ (ជាកំណាព្យ ) ខេមរៈ កាសិកជាកំណាព្យ (ល)

មានថ្វីដៃជាប់លេខមួយយកសញ្ញាប័ត្រអក្សរសាស្ត្រ ឆ្នាំ ១៩០២ . បានទទួលរង្វាន់លេខមួយក្នុងការប្រឡងប្រដែងអក្សរសាស្ត្រ ១៩៤២ ដោយវណ្ណកម្ម "ទាវឯក"

# រឿងតុងឈិន

## វគ្គទី១

មានសេចក្ដីដំណាលថា : កាលពុទ្ធសករាជកន្លងទៅបាន ១៩០០ ជាឬ ២០០០ ឆ្នាំ ព្រះមហាក្សត្រយ៍សោយរាជ្យសម្បត្តិគ្រប់គ្រងប្រទេសកម្ពុជាយើងនេះ ស្ដេចតាំងក្រុងនៅបន្ទាយលង្វែកជាព្រះរាជធានី ។

ក្នុងសម័យនោះមានស្ត្រីម្នាក់ឈ្មោះវណ្ណា នៅភូមិព្រាសាទ ខេត្តបន្ទាយមាស ។ នាងនេះជាតិខ្មែរ ឪពុកម្ដាយឲ្យមានប្ដី មានសែជាចៅចិនឈ្មោះតុងហួត ។ កាលដែលតាំងពីរនៅរួមរក្សាគ្នាជាស្វាមីភរិយា ក៏បង្កើតបានបុត្រម្នាក់ឲ្យឈ្មោះថា « តុងឈិន » ។ លុះតុងឈិនចំរើនបានអាយុ ៧ ឆ្នាំមានរូបកាយមាំមួន ព្រោះជាអ្នកមិនសូវមានរោគ កិរិយាឆ្លៀវឆ្លាសខុសពីក្មេងធម្មតា ។ បិតាបានបង្រៀនអក្សរខ្មែរ ចេះដឹងមើលសាស្ត្រាល្បែងដាច់បានសំគួរ ក៏នាំយកទៅឲ្យនៅរៀនអក្សរឯវត្ត គឺវត្តព្រាសាទ ។



គ្រូបានហ្វឹកហាត់តុងឈិនឲ្យមើលសាស្ត្រាទេសន៍ដាច់ ឲ្យរៀនលេខនព្វន្តខ្មែរនឹងចិន ចេះចែកចំណែកនឹងចំណោទ ឲ្យបាន បានឲ្យរៀនរាង ១ ឆ្នាំបិតាក៏មានជម្ងឺឈឺធ្ងន់ជាងបីខែទទួលអនិច្ចកម្មទៅ ។

តុងឈិនជាមនុស្សប្រកបដោយសេចក្ដីដឹងកតញ្ញូដឹងគុណបិតាមាតាណាស់ រកណិតម្ដាយមេម៉ាយក៏លាគ្រូមកនៅចាំរើម្ដាយ ។ គ្រូក៏អនុញ្ញាតឲ្យវិលមកវិញ តែមានសេចក្ដីស្ដាយណាស់ ព្រោះឃើញប្រាជ្ញានិងគំនិតមារយាទឆ្លាស់ហួតចត់ល្អខុសពីកូនសិស្សដទៃ តែនឹងឃាត់ពុំបាន ។ ឯកិរិយាតុងឈិន ច្រើនចូលចិត្តលេង ឬនិយាយ ឬ ស្ដាប់គេនិយាយតែខាងរឿងសេនាពាហន ។ កាលបិតានៅរស់ច្រើននិយាយរឿងផ្សេង ៗ ឲ្យកូនស្ដាប់ ដកប កូនចូលចិត្តស្ដាប់តែចំបាំង តាល់តែមានសេចក្ដីគិតបំណងទុក « ជាបើធំឡើង នឹងរៀនធ្វើសេនាពាហន » ។

កុងឈិនមកនៅបំរើមាតា មិនឲ្យមាតាព្រួយលំបាកសោះ គឺចេះស្លដណ្តាំបុកចេះស្លុអុំសៃយដូចស្រី ។ ពេលយប់ថ្ងៃចេះថែទាំចុកដាក់របស់ទ្រព្យ មិនឲ្យខូចខាតអន្តរាយដោយការធ្វេសប្រហែស ។ លុះកុងឈិនអាយុបាន ១៤ ឆ្នាំម្ដាយចង់ឲ្យកូនបួស ។ ពេលនោះកុងឈិននិយាយទៅកាន់ម្ដាយ ៖ ខ្ញុំបាទបួសមិនបាន ព្រោះអ្នកម្ដាយនៅតែឯង និងបានអ្នកណានៅក្បែរ នឹងបានអ្នកណាទៅបំរើ មួយទៀតខ្ញុំបាទគ្រាន់តែនឹក ១ ថា ៖ « ខ្ញុំបាទចំរើនមុខជាទៅធ្វើទាហាន » ។

ម្ដាយឮដូច្នោះក៏ឈប់និយាយ តែនឹកក្នុងចិត្តមិនចង់ឲ្យកូនឃ្លាតទៅឆ្ងាយ ចេះតែគិតរកឧបាយ ដើម្បីនឹងចង់កុំឲ្យកូនឃ្លាតពីខ្លួន ។ តែកុងឈិនបានចេះវិជ្ជាគុនស្រច្រើនប្រការ ។ ព្រោះសម័យនោះរកការឲ្យអំណាចប្រ



ជាជនបង្កើតវិជ្ជាហាត់ប្រាណ មានរៀនគុនជំបង គុនដាវលំពែង-ដាល់ ដកថ្នាំគន់កាប់មិនមុត គុនបាញ់ធ្នូស្នា ។ល។ សូម្បីស្រុកណា ខេត្តណា ក៏មាននាម៉ឺនមន្ត្រីប្រជុំគ្នារៀនគុនវិជ្ជានេះឲ្យពូកែគ្រប់ៗ ខ្លួនរហូតដល់នាម៉ឺនធំ ១ មានលោកសេនាបតីជាដើម ។ ដូចមានលោកសេនាបតីខ្លះ ឬ ចៅហ្វាយស្រុកខេត្តខ្លះ ចេះតែវិជ្ជាមួយមុខនេះកើតជាផ្លូវវិជ្ជាឯទៀត ក៏អម្ចាស់ផែនដីលោកតាំងឲ្យធ្វើនាម៉ឺនធំ ១ រហូតដល់សេនាបតី ឬ ចៅហ្វាយស្រុកខេត្តឯកក៏មាន ។ ព្រោះជាន់នោះស្រុកខ្មែរ ឬ ស្រុកសៀម ស្រុកលាវនិងស្រុកយួន ច្រើនតាស់តែងគ្នាធ្វើសង្គ្រាមនឹងគ្នា ។

កុងឈិនអាយុបាន ១៦ ឆ្នាំនៅបំរើមាតា ។ មាតាគិតគួររកការិយាឲ្យ កុងឈិនប្រកែកមិនទាន់ចង់បាន មាតាក៏មិនស្ដាប់ ។ មាតាបានទៅដណ្ដឹងបុត្រីគេម្នាក់នៅក្នុង

ស្រុកជាមួយឲ្យជាភរិយាគុជឈិន តែគុជឈិនមិនដែលបានទៅឃើញរូបភាពនាងនោះ ជាយ៉ាងម្ដេចសោះ តាំងនិតមារយាទក៏ពុំបានដឹង ឬជាល្អ ឬអាក្រក់យ៉ាងណា ដៀ តាមគំនិតនឹងសេចក្ដីបង្គំរបស់មាតា ក៏ព្រមទទួលរៀបការយកនាងនោះជាភរិយា ។ នាងសារិកាជាភរិយាគុជឈិនមានអាយុដំណាល់គ្នា ។ កាលបានគ្នាជាស្វាមីភរិយាហើយ ក៏នាំមកនៅជាមួយនឹងមាតាមេម៉ាយ ។

ឯនាងសារិកា មានបងប្អូន៣នាក់ គឺប្រុស ១ ស្រី ២ ប្រុសបងបង្អស់ ស្រីមួយទៀតពៅបំផុត ម្ដាយឪពុកស្លាប់អស់ ។ គុជឈិននៅរួមរួមនឹងភរិយាជិត ១ ឆ្នាំមិនមានបុត្រនឹងគ្នាទេ ។ គុជឈិនបានសុំកូនឆ្កែគេ ១ យកទៅចិញ្ចឹមក្រោមផ្ទះ ។ ម្ដាយគុជឈិនបានពិនិត្យឃើញកូនឆ្កែ ក៏ប្រាប់ថា ឲ្យចិញ្ចឹមវាទៅចុះ កូនឆ្កែនេះមានលក្ខណៈល្អ គឺអណ្ដាតតាំព្រីងពស់មិនហ៊ានចឹក ចុង



កន្ទុយក៏វង់ចំឆ្អឹងខ្នង ចង្កក់ត្រង់ទីងម្ចាស់ គេហៅថាឆ្កែមិនបង់ម្ចាស់ ។

លុះកូនឆ្កែនោះធំឡើង ក៏តែងដេញខាំសត្វព្រៃរឿយៗ ពាំយកមកឲ្យម្ចាស់ ក៏ខាំបានពស់ជាច្រើនតែបើខាំបានពស់ស្លាប់ហើយ ក៏កាយដីជ្រៅ ហើយពាំពស់នោះទៅដាក់កប់ក្នុងរណ្ដៅ រួចក៏កាយដីលុបបាត់តែស្មើមាត់រណ្ដៅ ។ នៅពេលនាងសារិកា ឬ គុជឈិន ដើរទៅទីឯណាៗ ឆ្កែនោះតែងតែបោលតាមដរាប បើម្ចាស់ទៅបាត់មុនៗ ដឹងក្លិន តាមហិតក្លិនម្ចាស់រកទាល់តែជួបប្រទះ ។ អ្នកឯទៀតឲ្យចំណីក៏ស៊ីក៏មិនស៊ីទេ បើម្ចាស់ក៏ឲ្យចំណីទើបក៏ស៊ី ។

## វគ្គទី២

ក្នុងសម័យនោះស្រុកសៀមនឹងខ្មែរ កើតចំបាំងនឹងគ្នាជាដរាប ។ បុរាណច្រើននិយាយទុកថា ;

"ប៉ះសៀម ប៉ះយួន ឬ ប៉ះចាម" ។

ចៅហ្វាយស្រុកខេត្តបន្ទាយមាសទទួលបង្គាប់ពីកងការធំបានកេណ្ឌរាស្ត្រទៅធ្វើទាហានចំបាំង កេណ្ឌដោយរើសមុខយកតែឈ្មោះណាដែលមានកម្លាំងមាំមួន ហើយមានគុណវិជ្ជាចេះដឹងល្បីជាងគេ ។

គុណឈិនត្រូវចូលក្នុងកំណែន ទី ១ អ្នកមានសេចក្ដីក្រេកអរណាស់ព្រោះត្រូវនឹងបំណងចិត្ត តែមិនចេញកិរិយាឲ្យមាតានឹងកិរិយាយល់ថាជាខ្លួនមានចំណង់ចង់ទេ ។ មានថ្ងៃមួយនោះគុណឈិនចូលទៅជំរាបលាម្ដាយនឹងកិរិយា ថា: ខ្ញុំបាទត្រូវកំណែនលោកចៅហ្វាយស្រុក ឲ្យកេណ្ឌទៅច្បាំង ខ្ញុំបាទសូមលាអ្នកម្ដាយទៅស្អែកនេះ កងការគេត្រូវបញ្ជូនទៅបន្ទាយលង្វែក ។ មាតាឮដូច្នោះ ក៏មានសេចក្ដីព្រួយណាស់លាន់មាត់ថា ព្រោះកូនឯងប្រាថ្នាចង់ហើយ ស្មើរៀនតិះរេះខាងចំបាំងហ្នឹងហើយ បានជាគេតម្រូវលើខ្លួនៗ បើ



ដូចអ្នកឯទៀតដែលគ្មានវិជ្ជាដូចកូនឯង គេក៏នៅសុខឃើញមុខឪពុកម្ដាយនឹងកិរិយាបុត្រមិនឃ្លាតទៅណាឆ្ងាយ ។

កូនឆ្លើយថា អ្នកម្ដាយមានប្រសាសន៍នោះត្រូវហើយ តែមិនមែនត្រូវទូទៅទេ ខ្ញុំបាទយល់ថា "កើតមកជាមនុស្សនេះត្រូវមានសេចក្ដីកតញ្ញូនឹងមាតាបិតា គ្រូអាចារ្យ រហូតដល់ព្រះមហាក្សត្រ ដែលលោកជាម្ចាស់ផែនដី រក្សាសេចក្ដីសុខដល់គណាប្រជានុរាស្ត្រ ឥឡូវប្រទេសរបស់យើងកើតសឹកសត្រូវនឹងប្រទេសសៀម បើខ្ញុំបាទនឹងអ្នកដទៃគិតតែគំនិតមួយ ដូចគំនិតអ្នកម្ដាយមានប្រសាសន៍នេះ នឹងបានអ្នកណាចេញមុខជួយកម្លាំងព្រះរាជាបាន បើព្រះរាជាវិនាសទៅហើយ យើងជារាស្ត្រទាំងអស់គ្មាននឹងមិនវិនាសទេឬ ?" . . . ។

. . ខ្ញុំបាទរៀនវិជ្ជានេះ ប្រយោជន៍តែជាផ្លែកតញ្ញូនឹងព្រះរាជា រហូតដល់អ្នកម្ដាយឲ្យបានសេចក្ដីសុខ ព្រោះខ្ញុំបាទ

ចូលចិត្តថា "មនុស្សណា នៅក្រោមម្លប់ព្រះបារមីនៃព្រះរាជា បើមិនទាន់ធ្វើទាហាន ហៅថាមិនទាន់សងគុណព្រះរាជាទេ ទោះបានធ្វើការឯទៀតច្រើនយ៉ាងណាក៏ដោយ ព្រោះសេចក្តីភ័យព្រួយនៃព្រះរាជានោះ គ្មានអ្វីស្មើបច្ចាមិត្រពជសត្រូវទេ មុនដែលខ្ញុំបាទនឹងស្លាប់ ខ្ញុំបាទសុំធ្វើគរវៈទីនឹងព្រះរាជាឲ្យហើយសិនដែលហៅថារាជពលី ...” ។

មាតាគុនឈិនបានស្តាប់សព្វសេចក្តី ហើយក៏ក្រឡប់ឲ្យពរថា "បើកូនបានទៅធ្វើសង្គ្រាមនោះ សុំឲ្យកូនតាំងចិត្តតែម្យ៉ាងថា យើងមិនមែនជាអ្នកបៀតបៀនគេឲ្យគេវិនាសទេ យើងមកជួយការពារសេចក្តីអន្តរាយ ព្រះមហាក្សត្រិយ៍ និងជាតិសាសនារបស់យើង ឲ្យទៅជាសុខ តែប៉ុណ្ណោះក៏ជាការប្រពៃណាស់ ... ។

គង់ឈិនបានទទួលពរមាតា ក្រាបសំពះបីដងហើយ ក៏ចូលទៅរៀបប្រដាប់សម្រាប់ខ្លួន គឺគ្រឿងសស្ត្រាវុធនឹង



ស្បៀងអាហារសំពប់បរិភោគ ក្នុងពេលដែលចូលទៅធ្វើសង្គ្រាមជាប់ដៃគ្នាហួសវេលា ដែលត្រូវបរិភោគអាហារតាមធម្មតា ។ នោះបុរាណជាទាស់តែងធ្វើនុកឲ្យមានដកប គឺខាតែកផ្តាយដំណើបដាំឬចំហុយឲ្យឆ្អិន ហើយគេហាលថ្ងៃឲ្យពាល់តែក្រៀម រួចច្រកដាក់ក្នុងថង់ស្ពាយ ។ ឯថង់នោះដេរដោយសំពត់ស្បូវ ប្ដូរម្យ៉ាងយ៉ាងក្រាស ទទឹងសំពត់ប្រវែងមួយហត្ថ បណ្ដោយប្រវែងពីរហត្ថ ដេរភ្ជាប់មុខទទឹង ហើយស្នាក់ត្រង់កណ្ដាលប្រយោជន៍ទាំ តាក់ម្ខាង ដាក់សំពត់តាម្ខាង រួចចងស្ពាយនឹងស្មា ។

ពេលយប់ចូលដំណេកគុនឈិនក៏និយាយ រំលឹកករិយាឲ្យនៅរក្សាផ្ទះនឹងបំរើបំរេះមាតាកុំឲ្យមានអនាទរ ។ លុះព្រឹកឡើង គុនឈិនរៀបខ្លួនជាស្រេច គឺស្មាម្ខាងស្ពាយថង់ ស្មាម្ខាងស្ពាយដាវផ្គា លាករិយា និងសំពះលាមាតា ហើយក៏ចុះទៅដក្កត់ហៅថ្ពៃបកស្លាបក្បាល ហើយនិយាយ

ថា "អាពាលឯងត្រូវនៅចាំផ្ទះរក្សាម្ចាស់ឯងកុំទៅណា អញទៅច្បាំងមិនដឹងជាយូរ ឬ ឆាប់ទេ" ។ ឆ្កែនោះពាលក្បាលបន្ទិច បានជាឲ្យឈ្មោះអាពាល តាំងពីតូច វាក៏ដូចជាស្តាប់បានឮម្ចាស់និយាយដូច្នោះ វាបក់កន្ទុយលិទ្ធដៃ លិទ្ធជើងម្ចាស់ ហើយក្រោយនោះវាចេះតែអង្គុយលូ កុងឈិនដើរចេញទៅ វាចេះតែលូតាល់តែម្ចាស់វាបាត់ ។

លោកកៅហ្វាយស្រុកបន្ទាយមាស កេណ្ឌ បានពលហានឯក ២០០ នាក់ទៅដល់បន្ទាយលង្វែក ។ ក្នុងសម័យនោះ សៀមនឹងខ្មែរច្បាំងគ្នាដណ្តើមយកស្រុកបាត់ដំបងនឹងសៀមរាប មុនសៀមចាញ់ខ្មែរ មុនខ្មែរចាញ់សៀម ។

កុងឈិនទៅធ្វើការចំបាំងជាង ១ ឆ្នាំមិនបានវិលទៅស្រុកម្តងសោះ សំបុត្រស្នាមក៏មិនដែលបានសរសេរផ្ញើដំណឹងទៅមាតានឹងភរិយា ព្រោះរវល់តែដើរច្បាំង ។



## វគ្គទី៣

និយាយពីនាងសារិកា ដែលនៅនឹងនាងវណ្ណាជាម្តាយក្មេក កាលកុងឈិនជាស្វាមីនៅជាមួយ នាងនេះក៏យកចិត្តទុកដាក់បំរើម្តាយក្មេកនឹងស្វាមី មិនដែលឲ្យខាតអធ្យាស្រ័យ ។ កាលកុងឈិនចេញទៅច្បាំងហើយ នាងនេះក៏មិនសូវយកចិត្តទុកដាក់នឹងបំរើមាតាស្វាមី របស់របរធ្វើការងារនៅក្នុងផ្ទះក៏លះបង់មិនចង់ធ្វើ ច្រើនចូលចិត្តដើរទៅលេងផ្ទះគេរឿយៗ ទាល់តែស្មោយំជើង ។

## វគ្គទី ៤

សម័យនោះមានបុរសម្នាក់ឈ្មោះសាភយ នៅភូមិកំពែង ក្នុងខេត្តព្រាំង ជាប់សាច់ញាតិនឹងនាងសារិកា តែជាញាតិឆ្ងាយ ។ កាលណាសាភយពេញវ័យ សាភយតែងទៅមកឯភូមិព្រាសាទ ដល់ឃើញសារិកាពេញក្រមុំ

ជាប់ចិត្តស្រឡាញ់ ពាល់តែគេដឹងថាខ្លួនសាពយចូលចិត្តស្រឡាញ់នាងសារិកា គេក៏នាំគ្នាចំអន់ថា សមគ្នាជាប្តីប្រពន្ធ ។ ជនទាំងពីរក៏ទន់ចិត្តប្រតិព័ទ្ធតាមមាត់គេថា ។ សាពយតែងតែមកផ្ទះនាងសារិការឿយៗ គ្រាន់តែបំណងទុក "ជាគន់ទីងដណ្តឹងនាងសារិកាធ្វើប្រពន្ធ", ។

លុះនាងសារិកាបានទៅធ្វើភរិយាគុនឈិនហើយ សាពយនឹកស្តាយពេកណាស់ ព្រោះខ្លួនចាប់ពិសមិនទាន់គេ ។ កាលគុនឈិនរៀបការយកនាងសារិកាធ្វើជាភរិយា សាពយនៅជាប់ចិត្តស្តាយណាស់ ។ អ្នកកម្លោះបានលបមើលនាងញយៗ ស្គាល់រូបភាពគុនឈិនច្បាស់លាស់ប្រាកដ ។ ឯគុនឈិនមិនបានស្គាល់សាពយទេ ទាំងមិនបានដឹងរឿងរ៉ាវ ដែលសាពយនិងភរិយាខ្លួនជាប់និស្ស័យចិត្តប្រវត្តិរកគ្នាទៀតផង ។

កាលបើនាងសារិកា ប្រែភពកិរិយា បេះតែដើរ



លើផ្ទះគេ បោះបង់ការងារក្នុងផ្ទះសម្បែង នាងវណ្ណាជាម្តាយក្មេកស្តីលើកប្រដៅថា៖ " មេនាងឯងប្តីមិននៅ ឯងមិនត្រូវដើរលើផ្ទះគេ បោះបង់ការងារក្នុងផ្ទះសម្បែង ម៉ែពីឯងទុកជាក្មេកត្រចៀក ឯងមិនត្រូវប្រព្រឹត្តឲ្យខុសពីគន្លងច្បាប់ស្រីទេ ម៉ែនិយាយប៉ុណ្ណឹង ឯងល្មមស្តាប់បានហើយ" ។

នាងសារិកាមិនតបឆ្លើយសោះ មុនដំបូងគ្រាន់តែបន្ទយពេល គឺ "៣–៤ថ្ងៃដើរទៅលេងម្តង" ។

ដល់យូរទៅកូនប្រសានិងម្តាយក្មេកទៅជាចាស់គ្នាពេញទី ពីព្រោះរឿងនេះ ។ នាងសារិកាខឹងនឹងម្តាយក្មេក ក៏រើជញ្ជូនយករបស់ទ្រព្យខ្លួននិងរបស់ប្តី វិលទៅផ្ទះបងប្រុសនឹងប្អូនស្រី លែងទៅបករកម្តាយក្មេកសោះ ។

នាងវណ្ណាដឹងថាកូនប្រសាដាច់សាមគ្គីហើយ ក៏ទៅហៅកូនក្មួយបង្កើតម្នាក់ពីរនាក់មកនៅកំដរ ។

ឯបងប្រុសនាងសារិកា ក៏មានប្រពន្ធទៅនៅភូមិ ដោយខ្លួនឯងហើយដើរមួយព្រឹក ៗ នាងសារិកាក៏នៅនឹងប្អូនស្រី ។ ក្រោយនោះប្អូនស្រីនឹងនាងសារិកា កើតជំលោះទាស់ទែងគ្នា មិនតិចតួចដល់ពេញកាត់កាល់គ្នា លែងរាប់អានធ្វើបងប្អូន ។ ប្អូនស្រីនោះនៅក្រុំក៏ការមកទៅនៅនឹងបងប្រុស ។ ស្អប់ប្អូនស្រីនាំរឿងនាងសារិកាទៅប្រាប់ បងប្រុសក៏ចូលកាន់ជើងខាងប្អូនទៅ ទាល់តែឈ្លោះនឹងនាងសារិកាកាត់កាល់លែងរាប់អានគ្នា ជាបងប្អូនទៅទៀត ។

ឯអាពាលវិញ កាលនាងសារិកាវិលទៅនៅផ្ទះបងក៏ ក៏តាមទៅនៅផង តែយូរ ៗ រាប់កឯផ្ទះក្លាយគុំនុំនិងបក្ស មិនស្ងៀមទេ ។

សាកយដឹងថាគុំគួនទៅច្បាំងយូរទៅ នឹងដឹងថានាងសារិកាទាស់នឹងម្តាយក្មេក លុះក្រោយមកដឹងថាបងនឹងប្អូន



នាងសារិកាទាស់ទែងគ្នាកាត់កាល់គ្នា ដឹងថានាងសារិកានៅតែម្នាក់ឯង សាកយក៏ទៅរកនាងសារិកាពេលយប់ អាពាលគិតសុះទៅនាំសាកយ ។ គាប់ជួនពេលនោះនាងសារិកាគាន់ភ្ញើលឈរនៅដីក្រោឡុកទៅស្គាល់ច្បាស់ជាសា-កយ ក៏ខឹងអរណាស់ចុះអង្គុលក្បាលអាពាលថា « អា-ពាលកុំនាំគ្នាយើងទេ » ។

ក្តៅនោះដូចជាដឹងពេកណាស់ មិនចេះត្រូវឡូឡា ដូចក្តៅដ៏ទេ កាលឮម្ចាស់ថាដូច្នោះ ក៏បក់កន្ទុយហើយ ទៅហាក់ដើរសាកយ ។

នាងសារិកាក៏អញ្ជើញសាកយឡើងទៅលើផ្ទះ ។ ជាបន្ទាន់នោះនាង .. បងមាន ប្រពន្ធហើយឬនៅ ដែលអញ្ជើញមកនេះមានការអ្វី ? „

សាកយថា " បងមិនទាន់មានប្រពន្ធទេ ( សាកយឆ្លើយ ) ការដែលមិនទាន់គេប្រពន្ធ ព្រោះបងជាប់ចិត្តប្រ

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

ប្រតិព័ទ្ធអូនឯងៗ ដូចព្រេងកម្មនាំឲ្យបងចាំចិត្តតាំងពីកាលដែល យើងជួបប្រទះមុខគ្នាក្នុងគ្រាដែលអូនឯងនៅពុំទាន់មានស្វាមី ។ បងសូមកជួបអូនឯង ដើម្បីសួរបញ្ជាក់ដល់ដួងចិត្ត ព្រោះគ្រាដើមដែលយើងបានប្រក្ដិកគ្នានោះ សូម្បីភះលាយលេបបាត់ទៅហើយក្ដី . . . បើអូននឹងរំលឹកប្រមូលយកឲ្យវាកើតឡើងវិញតើបានឬមិនបាន ? ដែលបងបកនេះ, បងតាំងចិត្តជាស្រេចថា បើអូនឯងមិនទទួលជាការជួបបងប្រាថ្នាទេ បងក៏មិនថយក្រឡប់ទៅវិញទេបងសុខចិត្តស្លាប់នៅទីនេះ ។

នាងសារិកា អាណិតស្រឡាញ់កុងឈិនជាស្វាមីណាស់ ព្រោះគិតឃើញថា ''ចិត្តកុងឈិនជាប្រុសសុភាពល្អរមែងថ្នមស្រីណាស់ តាំងពីបានរួមគ្នាជាស្វាមីភរិយា កុងឈិនមិនដែលយកដៃមកគាន់ពាល់ឲ្យឈឺសង្កៀរដល់សាច់ទាំងមិនដែលស្ដីឬបន្ទោស ឬ ប្រើទឹកមុខជាបែបអាក់អន់ស្រ



ពន់ចិត្តដល់ម្ដងសោះ ។ តែពេលនេះស្វាមីក៏ទៅច្បាំងបាត់ដំណឹងជិតមួយឆ្នាំហើយ មិនដឹងជាស្លាប់ឬរស់ ខ្លួនអញក៏មានបាបគ្រោះនៅឯកាយចាស់ទីងម្ដាយរបស់គេ ជាទោសប្រមាថផុតវិស័យនឹងឲ្យជាវិញមិនកើត ទោះបើវិលមកវិញនឹងរួបរួមគ្នាទៅនៅជាមួយវិញក៏មិនបាន ។ ចិត្តប្ដីសោតគេក៏មនុស្សកតញ្ញូនឹងមាតាគេគ្មាននរណាដូច ឃើញប្រាកដថាគេគង់នឹងមិនភាបស្រឡាញ់ខ្លួនអញឲ្យស្មើនឹងមាតារបស់គេទេ ,, នាងសារិកាគិតក្នាន់ក្នាន់តែក្នុងចិត្ត គិតទៅគិតមកជាច្រើនសា ក៏ផ្ដាច់ចិត្តថា '' ត្រូវតែលះពីស្វាមី ,, ។ ឲ្យតែនិស្ស័យចិត្តជាលោកិយប្រថុជ្ជន មិនថាតែចិត្តនាងសារិកាទេ ទោះនរណា ៗ ក៏ដោយ ៗ បំណងអ្វីមិនស្មើបំណងប្រតិព័ទ្ធប្ដី ទីងប្រពន្ធសូម្បីកាលនៅមិនទាន់បែកបាក់គ្នា មានការទឹងទាស់ឈ្លោះដល់ជេរប្ដារជាទម្ងន់ណាស់ លុះវេលាព្រាត់ប្រាសចាកគ្នា មិនថាមុខជា

អស់ឃើញមុខគ្នាទៀតហើយ ដូចព្រាត់ស្លាប់ជាដើម ពោះ ចិត្តបុរសក្តីស្ត្រីក្តី រមែងសង្រេងសង្រែអាឡោះអាល័យគ្នាជាឯក្រោយ ដោយទម្ងន់ខានផ្តាំ ជួនកាលនឹកលើកអាល័យទាល់តែអស់អាយុក្សណក្ស័យក៏មាន ចិត្តស្ត្រីច្រើនស្អិតនិស្ស័យជានឹងបុរស ៖ ទំបីមានស្ត្រីខ្លះនៅមេម៉ាយ តាំងពីក្មេងមិនយកស្វាមីច្រើនជានឹងបុរសពោះម៉ាយ ។

ឯចិត្តនាងសារិកា ក្នុងគ្រាដែលកំពុងគិតអាណិតអាណាចខ្លួន ដោយផុតទីពឹងស្វាមី នឹងផុត សេចក្តីទីពឹងបងប្អូន ដោយទាស់ទែងកាត់កាល់គ្នា ក៏ដាច់ចិត្តគិតថាលះបង់ស្វាមីជាស្រេច លុះត្រឡប់ចិត្តគិតពីសេចក្តីកំសត់កម្រ ឃើញប្តីចិត្តល្អនឹងខ្លួនគ្មានទេស្តានសោះ នឹងគិតពីឃើញទោសកំហុស ដែល កិតជាមនុស្សត្រូសស្តាប់ផិតប្តី ភ័យនឹងបាបស្លាប់ទៅចុះនរកឡើងដើមរការដែក មានក្អែកក្អែកចឹកពោះពុះអវយវៈកងកាយ ដូចគំនូរតាំងឡាយ



ដែលមាននៅនាផ្ទាំងព្រះវិហារ ។ នាងសារិកានឹកអាឡោះអាល័យស្វាមីព្រមទាំងភ័យនឹងបាប ក៏យំអណ្តឹកអណ្តកនៅមុខសាកយមិននិយាយឆ្លើយតបសោះ ។

លាសាកយក៏អស់សំណើច ហើយសួរថែមទៀតថា

— បងសួរអូនឯងជាពាក្យគួរសមល្មមអូនឯងស្តាប់បានដោ ឆាយណាស់ ។ គួរតែអូនឆ្លើយតបហើសឲ្យបងបានដឹង ។ ម៉េចទៅជាយំជាទីងនឹងបងសួរ ឬអូនឯងឃើញថាពាក្យបងមិនសមគួរត្រង់ណា ?

នាងសារិកាក៏ងក់ដើម ខ្លួនណាស់ ទេះតែយំពុំឆ្លើយសោះ ព្រោះត្រេះរិះទៅនៅផ្ទុំត្រង់សេចក្តីអាឡោះអាល័យស្វាមីហើយភ័យនឹងបាប ។ សាកយថា បងដឹងច្បាស់ថាអូនឯងទាស់ឈ្មោះនឹងម្តាយក្មេក ដែកទៅនៅនឹងបងប្អូនគេក៏សួនឲ្យពប់អានជាសាច់សន្តានជាប់ស្រេចទៅហើយ ។ សព្វថ្ងៃនេះអូនឯងណាក់ចុះជាមនុស្សអនាថាឬអូននៅគ្រាថា

និងចង់ទៅការប្ដី ។ បងជានាំជូនទៅបាន តែប្អូនត្រូវ គិតឲ្យមុតមាំក្នុងប្រាណ កុំឲ្យខុសដល់ពីរដង ។ "ព្រោះ ស្វាមីនិងភរិយាបាននៅរួមសុខទុក្ខនឹងគ្នា សូម្បីតែមួយអាទិត្យគេក៏អាចស្គាល់ចិត្តគ្នាបានណាស់, ។ "បងដឹងច្បាស់ថា កូនចិនស្រឡាញ់ម្ដាយគេ គេកតញ្ញូនឹងម្ដាយ គេមិនមែន ស្ដាយខ្លួនឯងប៉ុន្មានទេ ។" ។ អ្នកឯងដែលឮដែរ ចាស់ទុំលោកច្រើននិយាយថា 'ប្រពន្ធគេបានដោយងាយ ឪពុកម្ដាយគេបានដោយក្រ" ឬប្អូនឯងមិនចង់បានឈ្មោះជាស្ត្រីក្បត់ចិត្តប្ដី ឬភ័យនឹងបាប បងនឹងជំរាបឲ្យចូលចិត្ត "កើតមកជាមនុស្សនេះគ្មាននរណាបេះគិតឲ្យល្អហួត ១ ជាតិបានទេ គង់មានពាស់ខុស បើមិនច្រើន ក៏តិច ការខុសនឹងត្រូវលោកត្រូវគិតកែកុំឲ្យធ្វើត្រូវមុនខុស" ។

នារីសារិកាស្ដាប់ចាន់អង់យំសោក ហើយនិយាយថា ទៀតខ្ញុំពុំទាំបាប់ដកបងពីចិត្តខ្ញុំគិតយ៉ាងណា ។ ទេ បះ



មានប្រសាសន៍មុនបង្អស់ពោះខុសសោះ ក្រោយបង្អស់ត្រូវពិត ។ ពេលនេះខ្ញុំសូមផ្ញើរូបកាយនឹងជីវិតលើបងហើយ សូមឲ្យបងមានមេត្រីការុណិកការបស់ខ្ញុំ ឲ្យដូចប្ដីខ្ញុំមុន ហើយយើងត្រូវដោះខ្លួនយ៉ាងប្រញាប់ ចេញទៅឲ្យផុតពីទីដែន ទើបអស់ភ័យអន្តរាយ ។

សាកយនឹងនាងសារិកា ក៏បានគ្នាជាគូសាហាយតាំងពីពេលនោះមក ។ តែមុនថ្ងៃនឹងរះ សាកយដោះខ្លួនទៅក្នុងឯទីដទៃក្រៅពីទីនោះ មិនឲ្យនរណា ៗ ដឹងសេចក្ដីថាអ្នកទាំងពីរនេះសាហាយនឹងគ្នា ។ កល់យប់គេលបមកជួបគ្នាជាដរាប ។

នាងសារិកា ប្រើៗបាយប្ដីឈើក្រោកមិនរួច ព្រោះត្រាំអត់មិនទទួលទានបាយមាន ១ ថ្ងៃ ២ ថ្ងៃឬ ៣ ថ្ងៃម្ដងក៏មាន ម៉្លោះហើយខ្លួនប្រាណ ក៏ស្គាំងស្គមថមថយកម្លាំង ចាល់តែលើកយកជើងក្រាន និងឆ្នាំងមកដាក់ក្បែរដំណេក

ដើម្បីឲ្យអ្នកស្រុកជិតខាងគេក្រឡេកឃើញថា " ឈឺដើរមិនរួចមែន " ។ ដោយយល់ឃើញការដូច្នេះអ្នកស្រុកក៏មិតែងទៅសួរគេការដើម្បីមិនសូវលោះថ្ងៃ ។

សាកយនឹងសារិកា គិតនាំគ្នាតែបំបាត់ដាន ។ គាប់ជួនថ្ងៃនោះមានស្ត្រីម្នាក់ស្លាប់គេយកទៅកប់ពីពេលថ្ងៃ។ លុះដល់ពេលយប់សាកយទៅគាស់ខ្មោចរួច លុបដីជាផ្នូដដែលវិញ ហើយក៏សុំយកខ្មោចនោះមកដាក់ត្រង់ដំណេកនាងសារិកា ។ ឯខ្លួននាងសារិកា សាកយក៏នាំទៅទុកនៅទីឆ្ងាយ តាំងពីពេលព្រលប់ព្រមទាំងរបស់ទ្រព្យស្រាលៗ ។ លុះដល់ពាក់កណ្តាលអធ្រាត្រ អ្នកស្រុកផ្ទះជិតខាងដេកលក់ស្កាត់ ។ សាកយក៏វិលមកដុតផ្ទះនោះ ឆេះជុំវិញហើយគេចចេញទៅ ។ ផ្ទះនោះនៅឃ្លាតពីផ្ទះឯទៀតភ្លើងឆាបមិនដល់ ។

លុះបានឃើញភ្លើងឆាបឆេះឡើងសន្ធោសន្ធៅដូច្នោះ



អ្នកស្រុកក៏ស្ទុះភ្ញាក់តែមកលត់ៗ ក៏មិនទាន់ ដឹងថានាងសារិកាឈឺជាប់ក្រោកពីគេងួលមិនរួច ភ្លើងរោលស្លាប់ទៅហើយ ។ អ្នកស្រុកក៏នាំគ្នា អាណិតអាណាចខ្លាំងណាស់

មានអ្នកខ្លះយំសោកអាល័យ ។ លុះព្រឹកឡើងរើបឃើញខ្មោចនោះភ្លើងឆេះអស់ដៃជើង ឯមុខមាត់ក៏ឆេះខ្លោច មើលស្គាល់មិនច្បាស់ តែអ្នកស្រុកសំគាល់ច្បាស់ ថាជានាងសារិកា ។

ចំណែកកាលវេលាយប់នោះ ក៏ទៅដេកឯផ្ទះម្តាយកុងឈិន លុះព្រឹកឡើងក៏មកឯផ្ទះនាងសារិកា ឃើញភ្លើងឆេះអស់ផ្ទះ បាត់ម្ចាស់រកពុំឃើញ ក៏ស្រែកលូក្មួងថ្ងៃនោះ ។ លុះដល់យប់ក៏វិលទៅនៅឯផ្ទះម្តាយកុងឈិនវិញ ។

សាកយនឹងនាងសារិកានាំគ្នាតែបានឆ្ងាយណាស់ផុតស្រុកដែនគេស្គាល់ ដឹងដូលរទេះជិះទៅច្រើនថ្ងៃដល់ខេត្ត

បាសាក់ ទៅសំណាក់នៅភូមិបាកលៃ ។ សាកយប្រែ ឈ្មោះជាព្រលិត នាងសារិកាប្រែជានាងបពាត ។ ឯនាងនេះកាលនៅពីក្រមុំចុកសក់ពួង ដល់មានប្ដីកាត់សក់ផ្រង កាលប្ដីចេញទៅចំបាំង មិនដែលកាត់សក់សោះ សក់ក៏ដុះវែងក្រឡប់ចុកបួងទៅវិញ ។ ដល់ទៅនៅស្រុកបាសាក់ស្លៀកខោដូចស្រីចិន ពាក់អាវឡៃតែង ប្រយោជន៍មិនឲ្យគេស្គាល់ ។ សម័យនោះស្រុកបាសាក់នៅជាទឹកដែនអស្ចារ្យដែនដីខ្មែរ ។

ឯខ្មោចដែលភ្លើងឆេះផ្ទះនោះ អ្នកស្រុកបានទៅដំកើម្ដាយគុណឈិននឹងបងប្អូននាងសារិកា ដែលប្រែឈ្មោះនាងជាបពាត អ្នកតាំងសពនាងគឺម្ដាយក្មេកនិងបងប្អូន កាលបើដឹងថានាងនេះ ភ្លើងឆេះស្លាប់ហើយក៏កើតសេចក្ដីការណ៍គគ្នាទៅយកខ្មោចនោះដុតឲ្យសុស ហើយបើយកឆ្អឹងទៅខ្ចប់និងសំពត់ដាក់ក្នុងវាន នាងវណ្ណនិម



លោកបង្សុកូល ហើយយកធាតុទៅផ្ញើទុកឯវត្តបាសាទ

វគ្គទី ៥

និយាយពីគុណឈិន កាលកងការខេត្តបន្ទាយមាសបញ្ជូនទៅដល់បន្ទាយលង្វែកនោះ មុននឹងទៅចំបាំងបានទៅគំនាប់មេទ័ព ។ ក៏ឲ្យចុះបញ្ជីក្នុងពួកពាហានលេខ ១ ។ ពេលយប់មួយនោះ អ្នកដើរទៅកេះផ្ទះស្នាក់ក្រៅពីពេនពាហាន ប្រយោជន៍ដើម្បីឲ្យបានជាទីពឹងទៅថ្ងៃមុខៗ

គុណឈិនបានទៅជួបស្គាល់តាតាស់យាយតាស់ពីរនាក់ប្ដីប្រពន្ធ ជាអ្នកលក់ដូរទំនិញបន្តិចបន្តួចក្នុងផ្ទះ មានកូនស្រី ១ ទើបនឹងពេញក្រមុំ ឈ្មោះតាពិជ័យ យាយតាព ។ កូនស្រីឈ្មោះនាងសារ៉េ អាយុ ១៥ ឆ្នាំ នាងនេះមានលក្ខណៈរូបភាពល្អណាស់ ចេះអក្សរលេខស្ទាក់ ចេះដេរគ្រែបពាក់ខាងការស្រីហត់ចត់ ។ គុណឈិនបានសុំតាពិជ័យយាយតាពធ្វើជាពុកម្ដាយធម៌ ; ឯតាយាយ

ទាំងពីរ  ក៏ឲ្យមាននិស្ស័យមេត្រីស្រឡាញ់គុនឈិនស្មោះ ត្រង់  ព្រមទាំងបុត្រីមិនមានសេចក្ដីរង្កៀស ។ គុនឈិន មិនបានទៅដេកឯកេង់ទាហានទេ  ទៅធ្វើការតែពេលថ្ងៃ លុះដល់ពេលយប់អស់កិច្ចការខាងទាហាន  ហើយក៏មក ដេកនឹងបរិភោគអាហារឯផ្ទះឧត្តុកធមិដេច ។

គុនឈិនទៅហ្វឹកហាត់ទាហានចំណានជាងគេ  ខាង ស្ទៀតរហ័សនឹងកាប់ចាក់ហើយរត់លឿនដូចសេះផាយ  រត់ លឿនចម្ងាយបាន ៤០០ សិនមិនហត់សោះ  តែហាត់ជិះ បួនរត់ ១០ សិន ២០ សិនហេតុដល់រយ  គឺ ១ ថ្ងៃរត់ លើស ១០ សិន ការរត់បាន ៤០ ថ្ងៃ លឿនឈ្នះគេបាន លេខ ១  រួចគេឲ្យរត់លោតកំពស់  ហាត់ចាល់តែលោត ឡើងលើខ្នងដំរីបាន គុនឈិនបានលេខ ១ ទៀត ។ ក្រោយ នេះគេឲ្យរៀនរត់កាត់ព្រៃឲ្យលឿនឆ្ងាយ  ទៅដល់ពលម្ខាង មុនគេ  បានលេខ ១ ទៀត ។



គុនឈិនបានលេខ ១ បីដង ។  លោកមេទ័ពធំតាំងឲ្យ ធ្វើមេទាហានកាន់កូនហាសិប គេហៅថាមេហាសិប (១) ។

កាលគុនឈិនទៅកំពុងហាត់ទាហាននោះ លោកមេទ័ព ឲ្យរើសសេះជំនិះសំរាប់ទាហានចូលច្បាំង ។  មានសេះ ច្រើនណាស់ដែលពន្ធដារផែនដីឲ្យទៅហ្វាយស្រុកគ្រប់ខេត្ត យកប្រាក់ពន្ធដារពីអ្នកស្រុក  ទុកសំរាប់ឲ្យទាហានជិះ ដើរច្បាំង ។

លោក.មទ័ព  ឲ្យពួកទាហានរើសសេះមួយម្នាក់តាម ស្រេចចិត្តតែគុនឈិនរើសសេះមិនចេះត្រូវចិត្តសោះ  ព្រោះ គុនឈិនចេះមើលលក្ខណៈសេះចំបាំង ដោយឧត្តុកធនិយាយ ពន្យល់ពីកាលនៅក្មេង  ក៏នៅចាំបាន ។

មានមួយថ្ងៃគុនឈិនមានឱកាសទំនេរ ក៏លានាយទៅ ក្រោយ  ទៅពីក្រុងលង្វែកមកលេងកំពង់លួង ដើម្បីប្រាថ្នា

១ គលពាលត្រី

ះកមើលសេះ ព្រោះស្រុកកំពង់លួងទីងទុគ្គ មានសេះច្រើន កាលមកកំពង់លួងហានកៀនតាហានដូចគ្នា មកជាមួយគ្នាបីនាក់ទីងខ្លួន ។

មានស្រីមេម៉ាយម្នាក់ ចិញ្ចឹមមេសេះមួយមានកូនឈ្មោលមួយអាយុបានជាង ២ ខួប នៅភូមិព្រៃកព្ជាក់ង មាត់ស្ទឹងត្រាំងពាន្ធខាងជើង កាលថ្ងៃម្ចាស់តែងតែស្រាយលែងមេសេះនឹងកូនឲ្យទៅស៊ីស្មៅឯវាល ។

មេសេះនោះច្រើនហែលទឹកព្រែកកំពង់លួង ឆ្លងមកស៊ីស្មៅខាងត្បូងមាត់ព្រែក ។ កាលណាមេហែលទឹកមក កូនក៏ម្រហែលតាមច្រើនតែបោលពីចម្ងាយយ៉ាងលឿនមកដល់មាត់ព្រែក ហើយលោតលែងត្រង់មាត់ច្រាំងចំពាប មុខដំបូងលោតបានខ្លី ធ្លាក់ទឹកហើយហែលទៅ លោតច្រើនដងតាល់តែដល់មាត់ព្រែកខាងត្បូងផុតទឹក ចួនកាលធ្លាក់ត្រង់ទឹកកក់ជាន់ដីបាន ។ ព្រែកនោះទទឹង៨



ព្យាមគឺ ១៦ម៉ែត្រលុះល្ងាចមេសេះហែលទៅក្រោយវិញ កូនសេះបោលលោតលែងទៅវិញ ដូចពេលដែលមកជាដរាប។

ក្នុងឈិនមកដល់កំពង់លួង ក្រឡេកពីចម្ងាយឃើញរូបកូនសេះស្គាល់ច្បាស់លក្ខណៈជាសេះចំបាំង ក៏សួរពត៌មានដឹងថា នាងមេម៉ាយជាម្ចាស់សេះ ក៏ទៅឯផ្ទះឲ្យច្រើមនុស្សទៅចាប់កូនសេះនោះមក ហើយក្នុងឈិនយកដៃស្ទាបក្បាល ស្ទាបកហូតដល់សក់ស្វាយ ហើយយកដៃស្ទាបខ្នងទះយ៉ាងធ្ងន់ដៃ ខ្នងកូនសេះមិនព្រើត ឬ ផុបបន្តិចសោះនៅនឹងដដែល ក៏ស្ទាបហូតផុតកន្ទុយ ។ កូនសេះនោះសម្បុរផ្លេមេឃ ។ ក្នុងឈិនដឹងថាកូនសេះនោះពេញលក្ខណៈល្អ ក៏និយាយនឹងស្រីមេម៉ាយជាម្ចាស់សេះថា ខ្ញុំបាទជានាយតាហានក្នុងកងការ លោកមេទ័ពប្រើពីចម្ងាយឲ្យមករកទិញសេះសំរាប់ចំបាំង ឥឡូវខ្ញុំត្រូវការទិញសេះនេះ សូមឲ្យអ្នកលក់ឲ្យខ្ញុំបាទចុះថ្លៃដាច់ស្រេចត្រឹម



បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.

ប៉ុន្មាន ? ឲ្យមានប្រសាសន៍តែមួយម៉ាត់ទៅចុះ ។ ឆាង ម្ចាស់សេះ មិនមែនចង់លក់កូនសេះនោះក្នុងពេលនោះទេ ព្រោះឃើញកិរិយាប្លែកជាងសេះដទៃ រំពឹងលក់ក្នុងពេល ដែលវាធំទៀតទើបបានថ្លៃច្រើន ។ លុះដល់ឃើញពួក ទាហានពលការមកនិយាយវិញ ទាល់គំនិតមិនហ៊ានប្រ-កែក ។ គាត់គ្រាន់តែជាកូនសេះនេះនៅក្មេងអាយុទើបបាន ពីរខួបនឹងជិះមិនទាន់ពេញការទេ តែបើពលការលោកត្រូវ ការហើយ ខ្ញុំមិនត្រូវប្រកែក ។ ពីថ្ងៃមុនមានគេតថ្លៃឲ្យ ខ្ញុំពីរណែន ខ្ញុំមិនព្រមលក់ ឥឡូវបើលោកត្រូវការសុំឲ្យ អាណិតខ្ញុំជាស្រីមេម៉ាយ ឲ្យថ្លៃតែត្រឹមគេឲ្យខ្ញុំមុន ខ្ញុំលក់ ជូនលោកចុះ ។

គុងឈិនមិនសុំមួយម៉ាត់សោះ ប្រាប់ថា ខ្ញុំយក ហើយ សូមឲ្យអ្នកប្រើកូនចៅឲ្យទៅជាមួយនឹងខ្ញុំតាមទៅ យកប្រាក់ចុះ ហើយគុងឈិននឹងកៀនទាហាន ក៏នាំសេះ



នោះទៅឯបន្ទាយ លៃគិតក្នុងចិត្តថា បើលោកមេទ័ព បន្ទោសបុមិនព្រមចេញប្រាក់ពលការឲ្យ នឹងសុំខ្ញុំប្រាក់ផ្-ទាល់ក្ដាយកមិសឲ្យម្ចាស់សេះ ។ លុះទៅដល់មេទ័ពក៏នាំសេះ នោះទៅជំរាបលោកសព្វគ្រប់ ។ លោកមេទ័ពក្រឡេក ឃើញរូបសេះ ក៏ពេញចិត្តសរសើរគុងឈិនថា ចេះទិញ សេះបានល្អ តែចង់ថ្លៃបន្តិច ហើយក៏បើកប្រាក់ពលការ ឲ្យបង់ម្ចាស់សេះ ។ គុងឈិនយកសេះនោះទៅក្រោលខ្លួន ឯង ។

## វគ្គទី ៦

ក្នុងសម័យនោះព្រះករុណាជាម្ចាស់ផែនដី សោយ រាជ្យនៅក្រុងលង្វែកទ្រង់ព្រះនាមព្រះបាទសម្ដេចព្រះពញា ឆិបតី ទ្រង់ឲ្យជ្រើសរើសស្ត្រីរូបល្អធ្វើជាទីព្រះស្នំ ។

មានមួយថ្ងៃពេជ្ឈអមាត្យបានទៅនិយាយនឹងគាពជ័យ យាយគាក សុំយកនាងសារគី ជាចៅការបស់គាត់ទៅ

ក្លាយហ្វូង ៗ កាយាយតាំងពីរបេះតែអន្ទ្រពេជបំរើ គេ
ក៏នៅទៅមកនិយាយបន្ទុំជារច្រើនថ្ងៃ ទាល់តែកាយាយតាំង
ពីក្លាយរឿងក៏ប្រាប់គុងឈិនថា ហ្វូងឲ្យមករើសយក
នាងសាគើ ជាពិការទៅធ្វើព្រះស្នំ ឯចិត្តយ៉េងតាំងពីមិន
ប្រាថ្នានឹងចង់ឲ្យកូនទៅធ្វើព្រះស្នំក្រមកាហ្វូងទេ ព្រោះ
ខ្លួនកាន់តែចាស់ណាស់ហើយ កូនតែមួយនឹងបាននេណា
ពិតក្តីក្រខ្លួន តែកូនយល់ឃើញដូចម្តេចឲ្យជួយពិ -
ចារណា ? ៗ

គុងឈិន ឮ មាតាបិតាថាដូច្នោះ ក៏នឹកចាន់ ហើយ
ដំណាចតបទៅវិញភ្លាម ? លោកឪពុកអ្នកម្តាយគិត
នោះមិនត្រូវចិត្តខ្ញុំសោះ ។ ខ្ញុំបាទយល់ឃើញថា មនុស្ស
យើងកើតមកក្នុងលោកិយ នេណា ៗ ក៏មានសេចក្តី
ប្រាថ្នាតែ ៤ យ៉ាងដូចគ្នា គឺប្រាថ្នាលាភ ១ យស ១
សរសើរ ១ សុខ ១ ជាដកប តែសេចក្តីប្រាថ្នានេះ



លោកមិនឲ្យធ្វើឲ្យលើសលុប ទាល់តែក្រឡប់ចុះខុសមិនគិត
យុត្តិធម៌ គឺប្រើដោយកាការកំហែងបំភិតបំភ័យ តែបង្ខំឲ្យ
ឲ្យតែបានបំពានលើសេចក្តីសុចរិត ៗ លោកត្រូវឲ្យស្វែង
រកលាភយសសរសើរនោះ ឲ្យបានតាមសម្មាភាព ៗ
ពេលនេះជាមហាបុញ្ញលាភមកដល់អ្នកឪពុកម្តាយនឹងនាងជា
ប្អូនហើយត្រូវតែទទួល ៗ . . ព្រោះបុកណាថា ធ្វើ
ចំការស្រែ ឬ ជួញប្រែផ្សែង ១ បើសំណាងយ៉ាំងហេងទី
បំផុតចេញខុនមួយបានចំណេញយ៉ាំងលើស ៗ ឯជំនួញ
គឺកប់ប្រសប់នឹងព្រះមហាក្សត្រយ៍ ដ៏មានមហិទ្ធានុភាពនេះ
វែមនឹមានចំណេញមួយជាមួយរយ មួយពាន់ ឬ មួយម៉ឺន
កប់មិនខ្ជួន ៗ ខ្ញុំបាទសូមឲ្យលោកឪពុកម្តាយរៀបចំខ្លួន
អ្នកប្អូនស្រីឲ្យជាស្រេចចុះ បើព្រះរាជបំរើលោកមកនិយាយ
ដោយស្រុះស្រួលម្តងទៀត យើងត្រូវតែលើកក្លាយដោយ
ស្មោះសរ មិនត្រូវអន្ទ្រកព្រះរាជបំរើទេ សុំឲ្យលោកឪពុក

ជៀវខ្ញុំបាទចុះ !

កុងឈិននិយាយហើយក៏រៀបខ្លួនចេញទៅធ្វើការទៅៗ ក្រោយនោះបន្តិច មានព្រះរាជបំរើចេញពីក្រុងព្រះបរមរាជវាំង សុទ្ធតែពួកចាស់ទុំស្រីៗ ច្រើននាក់មកនិយាយនឹងតាពីជ័យយាយតាពម្តងទៀត ៗ តាយាយក៏ព្រមលើកនាងសារគីជាធិតា ថ្វាយតាមពាក្យកុងឈិន កាលព្រះរាជបំរើនាំនាងទៅថ្វាយព្រះករុណា យាយតាពក៏ចូលទៅជាមួយ ៗ

ខណៈនោះព្រះបាទសម្តេចព្រះមហាធិបតីទ្រង់សព្វព្រះទ័យនឹងនាងសារគីលើសស្រីស្នំទាំងឡាយ ព្រោះឃើញនាងបេះដូងត្រៀវត្រាស់ ព្រមទាំងគំនិតមារយាទ នឹងរូបឆោមក៏ល្អជាងគេ ព្រះករុណាទ្រង់តាំងជាស្នំឯក ៗ ឯតាពីជ័យយាយតាព ព្រះមហាក្សត្រក៏ទ្រង់ប្រោសឲ្យមានបៀវត្ស នឹងឲ្យមានពលកម្មោះចេញចូលបំរើជាវេន ៗ



នាងព្រះស្នំឯកនឹងតាពីជ័យយាយតាព ក៏រីករាយស្រឡាញ់មិនមិនលើកដល់គុណូបការរបស់កុងឈិន ដែលលើក ត្រូវទុកកុងឈិនដូចជាអ្នកមានគុណមួយយ៉ាងខ្ពស់ថ្លៃ ៗ

## វគ្គទី ៧

កុងឈិនបានដឹងថា ព្រះករុណាជាម្ចាស់ផែនដីទ្រង់សព្វព្រះទ័យប្រោសនាងសារគីជាប្អូនធម៌ លើកជាព្រះស្នំឯកហើយ ក៏មានអំណរអរក្រៃពេកណាស់ៗ កុងឈិនមកហាត់ក្បួនទាហានទៅក្នុងក្រុងលង្វែក បានប្រហែលបីខែ ៗ លោកមេទ័ពក៏លើកទ័ពចេញទៅច្បាំង ពួកស-ត្រូវដែលចូលមកក្នុងខេត្តបាត់ដំបង សៀមរាប នឹងស្ទឹងត្រែង បានរាបទាប ដោយកម្លាំងថ្មីដៃទាហានឯក មានកុងឈិនជាដើម ព្រោះកុងឈិនជាមនុស្សមានកម្លាំងខ្លាំងពូកែ មានសេះជំនិះក៏ពូកែលឿនរហ័សជាងសេះក្នុង

បំណាមសេះកងទ័ព ។ សេះនេះអាចអត់ទឹកអត់ស្មៅបានបីថ្ងៃ នៅពេលការចូលក្នុងសង្គ្រាមម្តង ៗ ។ ឯគុងឈិនក៏គេលើកចូលទៅកាប់ពួកសត្រូវបានរហ័ស ហើយគេបត្រឡប់មកវិញ សត្រូវដេញមិនទាន់ ខ្លួនក៏គង់កាប់មិនមុត ។

លោកមេទ័ពពេញចិត្តស្រឡាញ់គុងឈិនទុកជាសេនាឯកក្នុងកងទ័ព ។ ក្រៅពីគុងឈិន មានតែពួកទាហានក្នុងខេត្តស្ទោងពូកែច្បាំងបន្ទាប់ពីគុងឈិន សុទ្ធតែមានចិត្តស៊ូមិនខ្លាចស្លាប់ ទើបមានចំណាប់ពាក្យបុរាណនិយាយជាប់មាត់មកថា " សេនាទៅច្បាំង បំបាំងនៅស្ទោង " ។ បើខេត្តកំពង់ស្វាយបះ បានតែយកទាហានខេត្តច្បាំងសង្កត់ទើបឈ្នះ ។ បើខេត្តច្បាំងបះវិញ បានតែយកទាហានខេត្តកំពង់ស្វាយទៅសង្កត់ទើបសង្កត់ឈ្នះ ។ ក្នុងប្រទេសកម្ពុជាមានឫទ្ធិពូកែតែខេត្តពីរជាងខេត្តឯទៀត ។

ឯខេត្តស្ទោងគឺបំបែកចេញមកពីកំពង់ស្វាយ ។ ខេត្ត



កំពង់ស្វាយ និងខេត្តច្បាំងធំជាងគេ ។ ខេត្តបន្ទាយមាស គឺបំបែកពីច្បាំង ទើបបានពាក្យហៅថាច្បាំងក្រើយក្បួន ច្បាំងក្រើយដើងទល់សព្វថ្ងៃនេះ ។

## វគ្គទី ៨

កាលធ្វើទ័ពខាងព្រំប្រទល់ដែនខាងទិសពាយ័ព្យទិសឧត្តរ និងទិសឦសានបានកបចាបពេញមួយឆ្នាំ លោកអ្នកឧកញ៉ាពិជ័យសង្គ្រាមជាមេទ័ព បានបញ្ជូនសំបុត្រចូលមកបន្ទាយលង្វែក សូមឲ្យលោកសេនាបតីក្រាបបង្គំទូលព្រះករុណា សូមទ្រង់ជ្រាប និងសូមថយទ័ពត្រឡប់មកក្រុងវិញ ។ ព្រះករុណាក៏ទ្រង់ព្រះបរមរាជានុញ្ញាត នោះលោកពិជ័យសង្គ្រាម ក៏ថយទ័ពចូលមកដល់បន្ទាយលង្វែក ហើយបានធ្វើសេចក្តីកត់ហេតុរាយរឿងពីការដែលច្បាំង និងរាយរឿងពីថ្ងៃដែលទាហានឯក ទោ ត្រី ដែលមានថ្វី សុំឲ្យឡើងយសសក្តិតាមគុណានុរូបផាល់ផាប់គ្នា ។

ព្រះករុណាក៏ទ្រង់ប្រោសព្រះរាជទាន តាំងគុនឈិនជាសេនាធិកសក្តិ ៤ ពាន់(១) ឆាជាហ្លួនសក្តាបុទ្ធៃក្រ កាន់កូនទាហាន ៥០០ ហៅថាមេយេ ។

## វគ្គទី ៩

លោកសម្តេចចៅហ្វាទលហៈឈ្មោះគិនផាំងជាអធិបតីលើសេនាបតីក្រុមរដ្ឋមន្ត្រីជារាជគ្រូហ្លួនព្រះមហាធិបតី តាំងពីហ្លួននៅកុមារចៅហ្វាបានបង្រៀនវិជ្ជាអក្សរសាស្ត្រ ទាល់តែហ្លួនចេះដឹង ហើយបានជួយទំនុកបំរុងឲ្យហ្លួនបានទទួលរាជសម្បត្តិជាអម្ចាស់ផែនដី ។

ហ្លួនព្រះមហាធិបតី ទ្រង់ដឹងគុណូបការៈ ជួយចៅហ្វាបានឡើងជាតាំងហ្លួងព្រះឃ្លាំងមហាសម្បត្តិ រួចឡើងជាទីសេនាបតី ហេតុដល់ទល់សម្តេចចៅហ្វាទលហៈខ្ពស់បំផុត ។ តែលោកនេះខ្វះគុណសម្បត្តិដែលមានក្នុងខ្លួនច្រើន ១ ច្រើនប្រកបដោយសេចក្តីលោភយសសក្តិនិង ទ្រព្យ

(១)= អនុសេនីយទោ



សម្បត្តិទំនុកបំរុង បំពោះតែសាច់ញាតិវង្សត្រកូលរបស់ខ្លួន ឯអ្នកដទៃនោះមានគេម្រេះចេះដឹងឬមានគុណបំណាច់ឡើយ ហាក់ទឹងរាជការយ៉ាងណា បើអ្នកនោះមិនទៅមកចុះចូល មិនជួយទំនុកបំរុង ចូនកាលត្រឡប់គេរឿងអ្នកល្អឲ្យខូចយសសក្តិ-ទ្រព្យរបស់ក៏មានច្រើន ទាល់តែមនុស្សគ្រង់ល្អជៀសវាងមិនចូលជាពួក សុំលាចេញពីរាជការក៏ច្រើន ដែលមានជាពួកក្រុមលោកនោះ សុទ្ធតែមនុស្សចិត្តទុច្ចរិតកក្រក់ពេញតាំងស្រុកក្រុងនិងខេត្តក្រៅ ។

កាលគុនឈិនចេញពីក្រុងលង្វែកទៅច្បាំង ព្រះម្ចាស់សាគើ ទីព្រះស្នំឯក មានគភ៌គ្រប់ ១០ ខែហើយ ។ ព្រះនាងទ្រង់បានប្រសូតព្រះរាជបុត្រមានព្រះរូប និងលក្ខណៈល្អ មានព្រះលឹងផ្ទៀសទ្រលុកៗ ។

ព្រះករុណាជាព្រះវររាជបិតា ទ្រង់សព្វព្រះរាជហឫទ័យណាស់ ។ ព្រោះព្រះអគ្គមហេសីនិងព្រះស្នំឯទៀត